អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញ “សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ”លើបណ្តឹងឧទ្ធរណ៍ចំនួនប្រាំក្នុងសំណុំរឿង០០៤។ កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយ (“ដីកាបញ្ជូនរឿងទៅជំនុំជម្រះ”) សម្រេចបញ្ជូន យឹម ទិត្យ ទៅជំនុំជម្រះ ខណៈនៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតជាតិក៏បានចេញដីកាលើកលែងការចោទប្រកាន់ប្រឆាំង យឹម ទិត្យ (“ដីកាលើកលែងចោទប្រកាន់”)។

## សេចក្តីសម្រេចរួម៖ សម្រេចជាឯកច្ឆ័ន្ទដោយអង្គបុរេជំនុំជម្រះ

អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (កថាខណ្ឌ ៣៩ កថាខណ្ឌ ៤១ និង កថាខណ្ឌ ៤៣) និង បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ (កថាខណ្ឌ ៤៥) អាចទទួលយកបាន។ ចំពោះបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទី២.២ មូលដ្ឋានទី៣ មូលដ្ឋានទី៤ និងមូលដ្ឋានទី៥ អាចទទួលយកបាន (កថាខណ្ឌ ៥៧-៦៦) និងបដិសេធមូលដ្ឋានដែលនៅសេសសល់ថាមិនអាចទទួលយកបាន (កថាខណ្ឌ ៦៧-៨៣)។

ជាបញ្ហាបឋម អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នាចំនួនពីរក្នុងពេលដំណាលគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ដែលរំលោភទៅលើក្របខណ្ឌគតិយុត្តនៃ អ.វ.ត.ក (កថាខណ្ឌ ៨៤-១១៥)។

ដោយហេតុថា អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្ររបស់ចៅក្រមយ៉ាងហោចណាស់ចំនួនបួនរូប ដើម្បីចេញសេចក្តីសម្រេចផ្អែកលើសំអាងហេតុរួមលើអង្គសេចក្តី មតិយោបល់របស់សមាជិកផ្សេងៗគ្នានៃអង្គបុរេជំនុំជម្រះត្រូវបានភ្ជាប់មកជាមួយសាលដីកានេះ។ សាលដីកានេះបិទផ្លូវតវ៉ា (កថាខណ្ឌ ១១៦ ទំព័រ ៦៩)។

## យោបល់ចៅក្រមជាតិ

ដោយរម្លឹកដល់គោលបំណងជាមូលដ្ឋានរបស់ អ.វ.ត.ក ក្នុងការជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះពិចារណាឃើញថា អ.វ.ត.ក គឺជាតុលាការពិសេសដែលមាននីតិវិធីចោទប្រកាន់ និងនីតិវិធីផ្លូវតុលាការដោយឡែក ហើយថា ពុំមានបុគ្គលណាផ្សេងនៅសេសសល់ ដែលត្រូវយកមកចោទប្រកាន់ និងកាត់សេចក្តីនៅចំពោះមុខ អ.វ.ត.ក (កថាខណ្ឌ ១១៧-១២៣, ១២៥-១២៩) នោះទេ។ ចៅក្រមជាតិពិចារណាបន្ថែមទៀតថាការស៊ើបអង្កេតបឋមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបានធ្វើឡើងជាឯកតោភាគីហើយដោយសហព្រះរាជអាជ្ញាជាតិពុំបានដឹងនោះ នាំឲ្យមានអនីត្យានុកូលភាពចំពោះសំណុំរឿងនេះទាំងមូល (កថាខណ្ឌ ១៣០)។

ទោះបីចៅក្រមជាតិសន្និដ្ឋានថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា គឺខុសច្បាប់ក៏ដោយ ក៏ចៅក្រមជាតិបានសម្រេចថា យឹម ទិត្យ មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់តុលាការនេះទេ ហើយការលើកលែងចោទប្រកាន់លើសំណុំរឿងនេះ គឺជាការត្រឹមត្រូវ។ ហេតុនេះ ចៅក្រមជាតិបានសន្និដ្ឋានបិទសំណុំរឿង ០០៤ ប្រឆាំង យឹម ទិត្យ ដោយបញ្ជូនសំណុំរឿងនេះទៅតម្កល់ទុកក្នុងបណ្ណសារ (កថាខណ្ឌ ១៣១)។

## យោបល់ចៅក្រមអន្តរជាតិ

ចំពោះបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងដីកាដំណោះស្រាយចំនួនពីរ ដោយយល់ឃើញថាមិនបានរំលោភលើគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ឬសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នោះ ចៅក្រមអន្តរជាតិមិនព្រមបដិសេធដីកាដំណោះស្រាយផ្ទុយគ្នាទាំងពីរ ដោយផ្អែកលើមូលដ្ឋានអនីត្យានុកូលនៃការចេញដីកាទាំងពីរនេះឡើយ (កថាខណ្ឌ ១៦១-១៦៧)។ ចៅក្រមអន្តរជាតិបានសន្និដ្ឋានថា ដីកាលើកលែងការចោទប្រកាន់ពុំមានមូលដ្ឋានគតិយុត្តិ និងទុកជាមោឃៈ។ ចៅក្រមអន្តរជាតិបង្ហាញសំអាងហេតុថា ប្រការនេះបានរំលោភទៅលើគោលការណ៍បន្តកិច្ចស៊ើបសួរ និងការចោទប្រកាន់ ដែលបញ្ញត្តិអំពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត (កថាខណ្ឌ ១៦៨-១៧៧)។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ទោះបីជាមានការព្រមព្រៀងគ្នាដោយកំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការចេញដីកាដំណោះស្រាយចំនួនពីរក្នុងពេលដំណាលគ្នាក៏ដោយ ដោយហេតុថាដីកាបញ្ជូនរឿងទៅជំនុំជម្រះអនុលោមទៅតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក។ បណ្តឹងឧទ្ធរណ៍នេះត្រូវបានបដិសេធ (កថាខណ្ឌ ១៧២, ១៧៥-១៧៧)។

ចំពោះបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសន្និដ្ឋានថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិពុំមានកំហុសក្នុងការសន្និដ្ឋានថា យឹម ទិត្យ ស្ថិតក្នុងចំណោមជន

ទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត និងស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក (កថាខណ្ឌ ១៧៨-៤៧៦) ចៅក្រមអន្តរជាតិបដិសេធបណ្តឹងឧទ្ធរណ៍នេះ និងសម្រេចតម្កល់ទុកជាបានការចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ (កថាខណ្ឌ ៤៧៧-៤៧៨ ទំព័រ ៣១៣)។

ចំពោះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចៅក្រមអន្តរជាតិបដិសេធបណ្តឹងឧទ្ធរណ៍នេះ ដោយហេតុថាបណ្តឹងឧទ្ធរណ៍នេះពុំបានបង្ហាញនូវកំហុសឆ្គងណាមួយឡើយ (កថាខណ្ឌ ៤៩០-៤៩៧)។ ចៅក្រមអន្តរជាតិប្រកាសថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ និងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់ ត្រូវចាត់ទុកជាអាសាបង់ ដោយហេតុថាដីកាលើកលែងការចោទប្រកាន់ត្រូវបានទុកជាមោឃៈ (កថាខណ្ឌ ៥១០, ៥១៥)។

ជាសេចក្តីសន្និដ្ឋានចុងក្រោយ ចៅក្រមអន្តរជាតិសន្និដ្ឋានថា អនុលោមតាមវិធាន៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ក្នុងករណីមិនអាចរកបានសំឡេងភាគច្រើនតាមការតម្រូវដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ អង្គជំនុំជម្រះសាលាដំបូងត្រូវទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងអនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតត្រូវបន្តកិច្ចនីតិវិធីស្របតាមសេចក្តីពិចារណា (កថាខណ្ឌ ៥២២-៥២៣)។

លើសពីនេះទៀត ចៅក្រមអន្តរជាតិបានសន្និដ្ឋានថា អង្គហេតុព្រហ្មទណ្ឌដែលបានបង្ហាញនៅក្នុងសំណុំរឿង០០៣ និង សំណុំរឿង០០៤ ស្នើឲ្យមានការពិចារណាជាបន្ទាន់ទៅលើការចោទប្រកាន់ធ្ងន់ធ្ងរនានាទាក់ទិននឹងការទទួលខុសត្រូវរបស់អាជ្ញាធរតុលាការកម្ពុជា ក្នុងនោះរួមមានកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា អនុលោមតាម មាត្រា VI នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ (កថាខណ្ឌ ៥២៤-៥៣៩)។

សាលដីការបស់អង្គបុរេជំនុំជម្រះមានដាក់ផ្សាយនៅលើគេហទំព័រ៖ [https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D381_45_KH.PDF](https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D381_45_KH.PDF)

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក នេត្រ ភក្ត្រា**

ប្រធានផ្នែកកិច្ចការសាធារណៈ និងជាអ្នកនាំពាក្យ

ទូរស័ព្ទ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦

អ៊ីមែល៖ neth.pheaktra@eccc.gov.kh

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh